**មតិស្វាគមន៍**

**ឯកឧត្តម សៅ សុភាព នាយកខុទ្ទកាល័យនៃក្រសួងបរិស្ថាន**

**និងជាប្រធានក្រុមការងារចំពោះកិច្ចអន្តរក្រសួងរៀបចំឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣**

**ថ្លែងក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពី យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣**

***សណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦***

- *ខ្ញុំបាទសូមគោរព ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព*
- *សូមគោរព លោក Samiuela T. Tukufu នាយកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា*
- *ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល អស់លោក លោកស្រី នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូល ជាគោរព និងជាទីមេត្រី!*

ជាបឋម ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏កក់ក្តៅជូនចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលបានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពី «**យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣** (National Environment Strategy and Action Plan 2016-2023)» នាពេលនេះ។

ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកានៃអង្គពិធីទាំងមូល មេត្តាជ្រាបថា «យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ»នេះ គឺជាតម្រូវការចាំបាច់នាពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ជាអាទិ៍ ក្រសួង និងស្ថាប័នរដ្ឋនៅថ្នាក់ជាតិ និងរដ្ឋបាលក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងប្រទេសកម្ពុជាទាំងមូលយកទៅអនុវត្ត ដើម្បីរួមចំណែកសម្រេចឱ្យបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។

ដោយមើលឃើញនូវភាពចាំបាច់នេះ រាជរដ្ឋាភិបាលបានអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងបរិស្ថានសម្របសម្រួល និងដឹកនាំដំណើរការកសាងឯកសារយុទ្ធសាស្ត្រនេះ តាមរយៈលិខិតលេខ១០៦៩ សជណ.កស ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយប្រើប្រាស់ក្រុមការងារចំពោះកិច្ច ដែលមានសមាសភាពអន្តរក្រសួង ជាយន្តការទទួលបន្ទុកសម្របសម្រួល និងដឹកនាំកិច្ចប្រជុំបច្ចេកទេស និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នានា។ នៅក្នុងលិខិតអនុញ្ញាតរបស់រាជរដ្ឋាភិបាល ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើការត្រួតពិនិត្យ និងឆ្លងសេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តជាផ្លូវការ មុនដំណាច់ឆ្នាំ២០១៦នេះ។

ដូច្នេះ ដំណើរការនៃការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣ ត្រូវបានចាប់ផ្តើមក្នុងខែកញ្ញា ឆ្នាំ២០១៥ ហើយនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៦ នេះ។ សេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិនេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមគោលការណ៍ណែនាំស្តីអំពីការរៀបចំតាក់តែងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ខ្ញុំបាទសូមជម្រាបជូនឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស និងសមាជិក សមាជិកាទាំងអស់នៃអង្គពិធី ឱ្យបានជ្រាបផងដែរថា ដំណើរនៃការរៀបចំឯកសារយុទ្ធសាស្ត្រជាតិនេះ ត្រូវបានទទួលការគាំទ្រផ្នែកថវិកា និងបច្ចេកទេសពីមជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថាន(EOC) នៃធនាគារអភិវឌ្ឍន៍អាស៊ី ក្រោមកម្មវិធីបរិស្ថានស្នូលនៃមហាអនុតំបន់មេគង្គ ហើយមានការចូលរួមគាំទ្រពីបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ដៃគូរអភិវឌ្ឍន៍ និងផ្នែកឯកជនជាច្រើនទៀត។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ធនាគារអភិវឌ្ឍន៍អាស៊ី ក្រុមការងារ និងអ្នកជំនាញការមកពីមជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថាន ក្រសួង និងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងតែងតែផ្តល់កិច្ចសហការយ៉ាងល្អក្នុងការចូលរួមកសាងឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរព!*

ជួសមុខឱ្យក្រុមការងារចំពោះកិច្ចអន្តរក្រសួង ខ្ញុំបាទសូមអនុញ្ញាតគោរពរាយការណ៍ជូនអំពីវឌ្ឍនភាព និងសមិទ្ធផលសម្រេចបានរហូតមកទល់នឹងពេលនេះក្នុងការរៀបចំឯកសារយុទ្ធសាស្ត្របរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣ ដូចខាងក្រោម៖

- បានសិក្សាឯកសារសំខាន់ៗ និងរៀបចំរបាយការណ៍ចាប់ផ្តើម នៅក្នុងខែកញ្ញា និងតុលា ឆ្នាំ២០១៥។
- បានរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី១ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីចាប់ផ្តើមដំណើរការកសាងឯកសារយុទ្ធសាស្ត្រនេះ។
- បានរៀបចំបង្កើតក្រុមការងារចំពោះកិច្ចអន្តរក្រសួង ដែលមានសមាសភាពមកពី១៥ក្រសួង-ស្ថាប័នរដ្ឋ និងបានរៀបចំកិច្ចប្រជុំក្រុមការងារនេះចំនួនបួនលើក ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលក្នុងកែលំអសេចក្តីព្រាងឯកសារយុទ្ធសាស្ត្របរិស្ថាន។
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួនពីរលើក គឺនៅខេត្តព្រះសីហនុ និងខេត្តសៀមរាប។
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងកសាងសមត្ថភាពសហគមន៍មូលដ្ឋានស្តីពីយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣ នៅខេត្តកែប ព្រៃវែង កំពង់ធំ និងខេត្តបន្ទាយមានជ័យ។
- បានជួបពិគ្រោះយោបល់ដោយឡែក និងផ្ទាល់ជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីទទួលបានមតិយោបល់ និងធាតុចូលផ្សេងៗសម្រាប់សេចក្តីព្រាងយុទ្ធសាស្ត្រនេះ។

ជាក់ស្តែង រហូតមកដល់ពេលនេះ ក្រុមការងារបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសរុបចំនួន ២៧៤រូប មកពីក្រសួង-ស្ថាប័នរដ្ឋនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានអប់រំ និងសិក្សាស្រាវជ្រាវ ក្រុមការងាររៀបចំក្រុមបរិស្ថានជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។

ដូច្នេះ សិក្ខាសាលាថ្ងៃនេះនឹងផ្តល់ឱកាសជូនអ្នកពាក់ព័ន្ធទាំងអស់ជាថ្មីម្តងទៀត ដើម្បីធ្វើការពិនិត្យ ពិភាក្សា និងផ្តល់យោបល់ ដែលជាធាតុចូលដ៏សំខាន់សម្រាប់យកទៅធ្វើការកែលម្អ សេចក្តីព្រាងពេញលេញនៃឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣។ សេចក្តីព្រាងនៃឯកសារនេះ ចែកចេញជា៥ជំពូកធំៗ ដូចជា៖

- <u>ជំពូក១</u>៖ សេចក្តីផ្តើម និយាយអំពីគុណប្រយោជន៍ គោលបំណង និងវិសាលភាព
- <u>ជំពូក២</u>៖ ស្ថានភាពបរិស្ថាន និងធនធានធម្មជាតិ
- <u>ជំពូក៣</u>៖ ចក្ខុវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ ផែនការសកម្មភាព និងការអនុវត្តយុទ្ធសាស្ត្រនេះ
- <u>ជំពូក៤</u>៖ ហិរញ្ញវត្ថុ និងការត្រួតពិនិត្យ

- <u>ជំពូក៥</u>៖ សេចក្តីបញ្ចប់ (ជំហានបន្ទាប់)

នៅក្នុងកម្មវិធីទី២នៃអង្គសិក្ខាសាលាថ្ងៃនេះ ឯកឧត្តម **ទិន ពន្លក** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងឯកឧត្តម **ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គលេខាធិការផែនការនៃក្រសួងផែនការនឹងធ្វើបទបង្ហាញអំពីជំពូកសំខាន់ៗ របស់សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនេះ ដើម្បីជួយសម្រួលដល់កិច្ចពិភាក្សា និងការពិគ្រោះយោបល់។

ជាទិសដៅបន្ត ក្រុមការងារនឹង៖

- រៀបចំកិច្ចប្រជុំក្រុមការងារចំពោះកិច្ចអន្តរក្រសួង លើកចុងក្រោយ គ្រោងធ្វើនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ នៅក្រុងបាត់ដំបង ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចឯកភាពចុងក្រោយលើសេចក្តីព្រាងឯកសារ បន្ទាប់ពីទទួលបាននូវធាតុចូលពីអង្គសិក្ខាសាលានាថ្ងៃនេះ។
- កែសម្រួលសេចក្តីព្រាងចុងក្រោយជាភាសាខ្មែរ និងភាសាអង់គ្លេស។
- រៀបចំឯកសារ ដើម្បីដាក់ជូនក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ពិនិត្យ និងឆ្លងសេចក្តីព្រាងចុងក្រោយនៃឯកសារយុទ្ធសាស្ត្រនេះ។
- រៀបចំឯកសារ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តចុងក្រោយលើសេចក្តីព្រាងយុទ្ធសាស្ត្រនៅមុនដំណាច់ឆ្នាំ២០១៦ខាងមុខនេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសមាជិក សមាជិកានៃអង្គសិក្ខាសាលាជាទីគោរព!*

ដោយហេតុថា បរិស្ថានមានលក្ខណៈជាពហុវិស័យ ដូច្នេះការរៀបចំឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាព គឺតម្រូវឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលដៅលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។ ហេតុដូច្នេះ ក្នុងនាមក្រុមការងារ ខ្ញុំសូមសំណូមពរ និងអំពាវនាវដល់អ្នកពាក់ព័ន្ធទាំងអស់ មេត្តាចូលរួមឱ្យបានសកម្មបន្តទៀតក្នុងការផ្តល់នូវធាតុចូលសំខាន់ៗ ដើម្បីរៀបចំឯកសារនេះឱ្យបានសុក្រិត្យ គ្រប់ជ្រុងជ្រោយ និងអាចយកទៅអនុវត្តបានដោយជោគជ័យ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារសម្របសម្រួលសហប្រតិបត្តិការ ផែនការ និងថវិកានៃក្រសួងបរិស្ថាន និងអង្គភាពគាំទ្រកម្មវិធីបរិស្ថានស្មូលមហាអនុតំបន់មេគង្គ ដែលតែងតែបានខិតខំយកអស់កម្លាំងកាយចិត្ត ក្នុងការជួយជ្រោមជ្រែងដល់ដំណើរការនៃការរៀបចំឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ និងការរៀបចំសិក្ខាសិក្ខាសាលានាថ្ងៃនេះ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ឯកឧត្តម លោកជំទាវ លោក និងលោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលានាពេលនេះ ហើយខ្ញុំសូមគោរពជូនពរនូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ។